BBI0004

មជ្ឈមណ្ឌលឯកសារកម្ពុជា

**ឈួន ប៉ា , ភេទប្រុស K00307 (បាត់ខ្លួន)**

**គូនាទីមេក្រុម**

**សម្ភាសន៍ជាមួយ សួន រ៉ុត, អាយុ ៥៧ ឆ្នាំ "ត្រូវជាប្រពន្ធ"**

**នៅភូមិកណ្តាលត្បូង ឃុំគោកឃ្មុំ ស្រុកថ្មគោល ខេត្តបាត់ដំបង ។**

**ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦**

**សម្ភាសន៍ដោយៈ យិន ឆាយ**

ឆាយៈ សូមជំរាបជូនមីងពួកខ្ញុំធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលសិក្សាស្រាវជ្រាវពីរបប ប្រល័យពូជសាសន៍ខ្មែរក្រហមណឹងហ្នាស់ ដើម្បីចងក្រងជាឯកសារប្រវត្តិសាស្ត្រ ។ ទុកឲ្យក្មេងៗជំនាន់ក្រោយបានដឹង និងសិក្សារៀនសូត្រពីរបបណឹង ។ហើយម្យ៉ាងសំរាប់តំកល់ទុកជាឯកសារប្រវត្តិសាស្ត្រ នឹងឯកសារមួយចំនួនសំរាប់ទុកឲ្យផ្នែកច្បាប់នៅពេលលែតុលាការដំណើរការ ។ អីចឹងជំបូងខ្ញុំចង់ស្គាល់ឈ្មោះមីងមីងឈ្មោះអីដែរ?

រ៉ុតៈ ឈ្មោះ រ៉ុត..។

ឆាយៈ អីរ៉ុត មីង?

រ៉ុតៈ ដាក់ជីតាហ្អែស...?

ឆាយៈ បាទ!

រ៉ុតៈ មា៉ រ៉ុត ។

ឆាយៈ មីងមានអាយុប៉ុន្មានហើយ?

រ៉ុតៈ អាយុ ៥៧ ។

ឆាយៈ មីមានប្តីឈ្មោះអីដែរ?

រ៉ុតៈ ក្រោយនេះហ្អែស?

ឆាយៈ និយាយប្តីមុនសិន...

រ៉ុតៈ ប្តីមុនឈ្មោះប៉ា...ឈួន ប៉ា ។

ឆាយៈ មីងរៀបការជាមួយគាត់នៅឆ្នាំណា?

រ៉ុតៈ ឆ្នាំ ៧០ គត់ ។

ឆាយៈ បាំ កាលពីគាត់នៅក្មេងៗគាត់បានរៀនសូត្រ...ហើយមានបានបួសដែរទេ?

រ៉ុតៈ អត់គាត់បានរៀនបន្តិចៗគ្រាន់តែមើលអក្សរបន្តិចៗ ។

ឆាយៈ ហើមីងមានកំណើតកើតជានៅភូមិណាដែរពីដើមមៅ?

រ៉ុតៈ នៅភូមិនេះពីដើមមៅ ។

ឆាយៈ នៅភូមនេះគេហៅភូមិអី?

រ៉ុតៈ នៅភូមិកណ្តាលខាងត្បូង ឃុំគោកឃ្មុំ ស្រុកថ្មគោល ខេត្តបាត់ដំបង ។

ឆាយៈ ហើយអីចឹងសព្វថ្ងៃមីងមានគ្រួសារមួយទៀតឈ្មោះអីដែរ?

រ៉ុតៈ ឈ្មោះ សែម ។

ឆាយៈ គាត់អាយុប៉ុន្មានហើយ?

រ៉ុតៈ ក្រោយហ្អែស៎..។

ឆាយៈ បាទ!

រ៉ុតៈ ៤៨,៤៩ ហើយ ។

ឆាយៈ បាទ!

រ៉ុតៈ កូនក្រោយនេះមានតែមួយ ។

ឆាយៈ ហើកូនមុនប៉ុន្មាននាក់?

រ៉ុតៈ ១ ដែរស្លាប់ហើយ ។

ឆាយៈ ១ដែរប៉ុន្តែងាប់ហើយ..ស្រីឬប្រុស?

រ៉ុតៈ ស្រី ។

ឆាយៈ ចុះកូនក្រោយ?

រ៉ុតៈ ស្រី ។

ឆាយៈ ស្រីដែរ...នៅរស់?

រ៉ុតៈ ចា៎!

ឆាយៈ អាយុប៉ុន្មានហើយកូនណឹង?

រ៉ុតៈ ១៧ ។

ឆាយៈ បាទ! ហើមីងប្រកបរបបររកទទួលទានអីដែរសព្វថ្ងៃណឹង?

រ៉ុត: ធ្វើស្រែ ២ កូនរ៉ៃណឹង ។

ឆាយ: បាទ! ខ្ញុំចង់សួរនាំមីងពីរឿងប្ដីមីងមុនណឹងហ្មាស់..ឈ្មោះ ប៉ា ណឹងហ្មាស់ ពេលដែលគាត់ចូលបដិវត្តណឹងគាត់ចូលពីឆ្នាំណាដែរ?

រ៉ុត: ចូលពីឆ្នាំ ៧០ គត់ទាំងអស់គ្នា ។

ឆាយ: ចូលជាមួយមីងដែរហ្អែស់?

រ៉ុត: ចា៎!

ឆាយ: កាលណឹងមានព្រឹត្តិការអីកើតឡើងនៅក្នុងភូមិណឹង?

រ៉ុត: ទេស្រាប់តែឃើញគេរត់ៗនឹងគេទៅ ។

ឆាយ: រត់ទៅជាមួយគេរត់ទៅ នៅអីណាទេ?

រ៉ុត: នៅព្រៃ ។

ឆាយ: ហើអ្នកណាមៅបបួលទៅ?

រ៉ុត: អ្នកស្រុកយើងណឹងចេះតែរត់ទៅមិនដឹងខ្យល់អី នឹងគេទៅ ។

ឆាយ: ទៅទាំងអស់គ្នាទាំងគ្រួសារហ្អែ៎?

រ៉ុត: ចា៎! គេក៏ទៅ យើងក៏ទៅ ។

ឆាយ: ហើយើងទៅណឹងគេរើសធ្វើជាទ័ពហ្នឹងឬក៏ម៉េច?

រ៉ុត: មុនដំបូងធ្វើជាឈ្លបបន្តិចបន្តួចអីចឹងទៅ ។

ឆាយ: កាលណឹងឆ្នាំបន្ទាប់កាលណឹង?

រ៉ុត: ៧០ គត់អីណោះ ។

ឆាយ: ដូចថាអត់មានពីណាមៅឃោសនាថាយ៉ាងម៉េចៗទេបាននាំគ្នារត់ចូលព្រៃណឹង ។

រ៉ុត: អត់ទេទៅក៏ឃើញគេដើលក៏ដើល នឹងគេទៅ ។

ឆាយ: ហើទៅព្រៃណឹងអ្នកណាមេកើយអី?

រ៉ុត: មេកើយអ្នកស្រុកគ្នាឯងណឹង
មេក្រុមអីណឹងនៅជុំគ្នាទៅក្ដាប់គ្នាទៅមិនដឹងថាអ្នកណាអ្នកណី ទេ ។

ឆាយ: ហើពេលដែលយើងទៅព្រៃអីចឹងបានអីហូបទៅ?

រ៉ុត: ស្រូវអង្ករយើងដឹកទៅ ។

ឆាយ: ដឹងស្រូវអង្ករពីនេះទៅហ្អែស?

រ៉ុត៖ ចា៎!

ឆាយ៖ ទៅនៅព្រៃណឹងបានប៉ុន្មានឆ្នាំ?

រ៉ុត៖ ៣ ឆ្នាំ ។

ឆាយ៖ ទៅនៅ ៣ឆ្នាំ.! គេហៅព្រៃអីទៅហ្នឹង?

រ៉ុត៖ គេហៅព្រៃកំពីងពួយ ។

ឆាយ៖ ទៅនៅហ្នឹងប្រហែលមនុស្សប៉ុន្មានគ្រួសារទៅ?

រ៉ុត៖ ក្រែលដែរនៅតាមព្រៃកំប៉េតកំប៉ូតគេក៏នៅ យើងក៏នៅមិនដឹងអ្នកណាអ្នកណី ។

ឆាយ៖ ទាំងគ្រួសារទាំងកូនទាំងចៅអីទៅទាំងអស់គ្នាហ្នងនែស៎?

រ៉ុត៖ ចា៎!

ឆាយ៖ ហីចុះប៉ាគាត់ចូលទៅ ធ្វើទ័ពគាត់ចូលពីឆ្នាំណា ដែលគាត់ទៅជាកងទ័ពហ្នង?

រ៉ុត៖ មិនដឹងជាឆ្នាំ ៧០ ប៉ុន្មាន...៧១មិនដឹង ៧២ មិនដឹងខ្ញុំមិនចាំផង ។

ឆាយ៖ បាទ! ហើយកាលទៅណឹងពីណាមោយកទៅ?

រ៉ុត៖ អត់មានពីណាមោយកទៅ ទេ...ទៅណឹងទៅ កើតនៅកំពីងពួយហ្នឹងហ្នង
កើតនៅអីព្រៃកំពីងពួយ ណឹងហ្នង ។

ឆាយ៖ ព្រៃកំពីងពួយណឹងហ្អែស៎?

រ៉ុត៖ ព្រៃខាងលិចកំពីងពួយណឹង គេរៀបចំម៉េចក៏រៀបទៅខ្ញុំក៏មិនដឹងដែរ ។

ឆាយ៖ បាទ! ហីគេឲ្យហាត់ក្បួនយុទ្ធសាស្ត្រអីយ៉ាងម៉េចដែរឬក៏អត់ទេ?

រ៉ុត៖ ហាត់ក្បួនយុទ្ធសាស្ត្រអីម៉េច...

ឆាយ៖ ហាត់បាញ់ហាត់លូនអីណឹងអ្ហ៎?

រ៉ុត៖ អូអាដល់ពេលគេចូលគេទៅហាត់អីណាក៏ខ្ញុំអត់ដឹងខ្ញុំនៅតែផ្ទះមើលកូន
ដូចថាគេបញ្ជូនឲ្យយើង ទៅអីចឹងមិនដឹងគេទៅហាត់អីណា ។

ឆាយ៖ ពេលគាត់ចូលទៅមានគេបញ្ជូនឲ្យទៅណាដែរ?

រ៉ុត៖ នៅហ្នឹងមានទៅណា ។

ឆាយ៖ នៅហ្នឹងតែរហូតទៅ...?

រ៉ុត៖ ចា៎!

ឆាយ៖ ចុះបែកឆ្នាំ ៧៥?

រ៉ុតៈ ដល់ឆ្នាំ ៧៦ នេះគេថានៅអីស្ពាពរអីចឹង..នៅក៏នៅទៅ ។

ឆាយៈ អត់ដែលបានទៅសួរនាំអីគាត់ទេ?

រ៉ុតៈ អត់ទេ ។

ឆាយៈ ហើគាត់ក៏អត់បានមៅលេងផ្ទះអីទេ?

រ៉ុតៈ គាត់មៅលេងមួយភ្លែតអីចឹងទៅ ជួនកាលមៅមួយភ្លែតទៅវិញទៅ ។

ឆាយៈ មៅអត់មានសួរនាំថានៅអីណាៗទេ?

រ៉ុតៈ ដែលបែកណឹងនៅស្ពាពរ ។

ឆាយៈ នៅស្ពាពរណឹងគេឲ្យធ្វើអី?

រ៉ុតៈ ធ្វើទ័ព ។

ឆាយៈ ចុះឆ្នាំ ៧៥ ដែលលន់ណុលចាញ់ណឹងគាត់ដែលមៅលេងផ្ទះទេ?

រ៉ុតៈ មៅតែគាមៅ ១យប់ ២យប់ទៅវិញទៅ ។

ឆាយៈ ពេលឆ្នាំ ៧៥ ណឹងពេលដែលគាត់មៅមានសួរគាត់ថានៅអីណាៗដែរទេ?

រ៉ុតៈ ខ្ញុំនោះមិនបានសួរនាំអីទេ នឹកឃើញខ្ជិលសួរគាត់ ដល់តែមៅបាត់នេះបែបនៅស្ពាពរនេះឯង ។

ឆាយៈ អីចឹងនៅស្ពាពរណឹងរហូតអីចឹង?

រ៉ុតៈ ចា៎!

ឆាយៈ ពេលបាត់មានដំណឹងដែរ? ពេលគេចាប់គេអីណឹងហ្អស៎?

រ៉ុតៈ អត់ទេ ..ដល់ពេលខ្ញុំអស់អង្ករទៅយកអង្ករបានខ្ញុំសួរគេ...សួរគេទៅស្រាប់តែគេប្រាប់ថាឃើញគេដឹកគាត់ទៅហើយ ។

ឆាយៈ មីងទៅយកអង្ករនៅអីណាបានៗជួបគេសួរគេ?

រ៉ុតៈ ទៅយកនៅមៅណក់ ពេលដែលរត់ហើយណឹង ។

ឆាយៈ អូ..!រត់ហើយហ្អែស៎?

រ៉ុតៈ រត់ហើយ ។

ឆាយៈ រត់ ៧៩ណឹង?

រ៉ុតៈ ចា៎! រត់ ៧៩ ណឹងដែលអត់អង្ករអត់អី...ទៅក៏ខ្ញុំសួរគាត់..គាត់ថាគេដឹកមៅកើតហើយខ្ញុំសួរគាត់ថាយ៉ាងម៉េបានគេដឹក...គេថាគាត់មេកង ។

ដល់ស្រាវជ្រាវទៅ ឃើញគាត់ជាមេក្រុម អីចឹងវាហួសទៅហើយ
ទោះបីទៅតាមក៏តាមមិនទាន់ដែរ ។

ឆាយៈ អីចឹងពេលដែលគេចោទថាមេកង
ហើយដល់ស្រាវជ្រាវទៅ ឃើញថាមេក្រុមក៏គេចាប់ទៅហួស ហើយ ។

វ៉ុតៈ ហ្នឹងហ្អើយគាត់ប្រាប់ខ្ញុំថាអីចឹង ។

ឆាយៈ ហីអ្នកដែលទៅណឹងតែទៅ ហើយមិនអាចយកម៉ៅវិញទេអីចឹង?

វ៉ុតៈ ចា៎! គាត់ថាតែទៅ ហើយមិនសាយយកម៉ៅវិញបានទេ ។

ឆាយៈ អីចឹងមីងស្គាល់អ្នកម៉ៅប្រាប់ណឹងទេមីង?

វ៉ុតៈ ខ្ញុំអត់ស្គាល់គេទេ ខ្ញុំសួរគេអីព្រៃងណោះតាមផ្លូវទៅស្ដាពរណឹងឯងទៅកាង៉ក់ណឹងណា ។

ឆាយៈ បាទ!

វ៉ុតៈ ទៅគាត់ប្រាបខ្ញុំថា គេយកទៅកើតហើយ ព្រោះអីគេថាគាត់មេកង ដល់ពេលនេះគាត់មេ
ក្រុមទៅយកម៉េចបាន ។

ឆាយៈ ហីគាត់អ្នកប្រាប់ណឹងគាត់បានឃើញផ្ទាល់ណឹងភ្នែកហ្អែស៎?

វ៉ុតៈ ខ្ញុំក៏មិនបានបញ្ជាក់គាត់ច្រើនទេ ។

ឆាយៈ បាទ!

វ៉ុតៈ បានគេប្រាប់ប៉ុណ្ណឹងអរគុណគេដែរ ។

ឆាយៈ អីចឹងគាត់ណឹងនៅអង្គភាពជាមួយគ្នា?

វ៉ុតៈ គាត់មិនមែនអង្គភាពជាមួយគ្នាទេតែគាត់ស្គាល់ ខ្ញុំសួរឈ្មោះថាប្ដីខ្ញុំនៅកង ៣៧០ ។

ឆាយៈ អូ..!សួរគាត់អ្នកប្រាប់ណឹងថាប្ដីមីងនៅកង ៣៧០ ចឹងហ្អែស?

វ៉ុតៈ សួរគាត់ថាប្ដីខ្ញុំឈ្មោះ ប៉ា នៅកង ៣៧០ រួចគាត់ថាគេយកទៅកើហើយធ្វើម៉េចតាមទាន់ ។

ឆាយៈ បាទ! អីចឹងមីងអត់មានសួរនាំគេដេញដោលអីគេទេនែស៎?

វ៉ុតៈ អត់ទេខ្ញុំអត់ហ៊ានសួរច្រើនទេ ។

ឆាយៈ ហីក្រោយម៉ៅអត់មានពីណាប្រាប់ថាត្រូវគេចាប់បញ្ជូនទៅភ្នំពេញទៅអីទេនែស៎?

វ៉ុតៈ អត់ដល់តែឥឡូវណឹង ។

ឆាយៈ ហីមីងក្នុងចិត្តរបស់មីងមានគិតថាគាត់នៅរស់ឬក៏យ៉ាំងម៉េចដែរ?

រ៉ុតៈ ខ្ញុំថាទៅកន្លែងណឹងដូចថាមិនសន្សឹមបានខ្ញុំកាត់ចិត្តទៅ ព្រោះទៅកន្លែងណឹងភាគច្រើនវាមិនរស់ ។

ឆាយៈ ចុះក្រោយ៧៩ម៉ោមានដើរស៊ើបសួរគេរកប្ដីរបស់មីងដែរទេ?

រ៉ុតៈ មិនដឹងទៅស៊ើអ្នកណាបើអ្នកស្រុកណឹងគាត់មិនសូវស្គាល់ប្ដីខ្ញុំផង ។

ឆាយៈ អីចឹងពេលដែលគាត់ចូលទ័ពមីងនៅឯណាដែរ?

រ៉ុតៈ នៅហ្នឹងជាមួយគ្នា ។

ឆាយៈ នៅកំពីងពួយណឹង?

រ៉ុតៈ ចា៎!

ឆាយៈ អូ..!គាត់នៅទ័ពគាត់នៅជាប្រជាជន?

រ៉ុតៈ ចា៎! ខ្ញុំនៅជុំគ្នាហ្នឹងឯង ។

ឆាយៈ នៅជុំគ្នាជាមួយគ្នារហូតទៅ?

រ៉ុតៈ ចា៎! គេធ្វើមេក្រុមមេកងអីចឹងទៅ ។

ឆាយៈ បាទ!

រ៉ុតៈ បង្កើតសហកណ៍អីចឹងទៅ ។

ឆាយៈ បាទ!

រ៉ុតៈ ប្ដីក៏ទៅៗប្រពន្ធក៏នៅទៅ ។

ឆាយៈ ប៉ុន្តែប្ដីទៅម៉ោៗ?

រ៉ុតៈ គាត់កម្រសូវម៉ោផង ទៅយូរៗណាស់ទំរាំគាត់ម៉ោលេងម្ដង ។

ឆាយៈ ហីមីងនៅកំពីងពួយណឹងគេបង្កើតសហករណ៍អីដែរហ្អេស៎?

រ៉ុតៈ គេបង្កើតដែរ គេដាក់ជាសហករណ៍ទៅដាំបាយរួមដាំអីចឹងណាស៎ ។

ឆាយៈ ហីចុះការងារធ្វើពលកម្មអីគេចែកជាកងជាក្រុមអីទេ?

រ៉ុតៈ ពលកម្មអីគេចែកជាក្រុមដែរតើស៎ ។

ឆាយៈ ចែកជាក្រុមជាកងអីដែរណែស៎?

រ៉ុតៈ ចា៎!ដាំពោតដាំអី ប៉ុន្តែធ្វើស្រែអត់ដែលធ្វើទេ ៣ឆ្នាំណឹងនោះ ។

ឆាយៈ អូ..!៣ឆ្នាំជាងណឹងអត់បានធ្វើស្រែទេនែស៎?

រ៉ុតៈ បាទ! ទើបតែធ្វើ ៧៥ តើស៎ ។

ឆាយៈ មុនឆ្នាំ ៧៥ណឹងអត់មានធ្វើស្រែទេ?

វ៉ុតៈ អន្ទុរពេលធ្វើហើយណឹងដឹកពីចកទៅវិញ ។

ឆាយៈ អូ!គេដឹកពីចកទៅខបត្ថម្ភនៅហ្នឹង?

វ៉ុតៈ ខបត្ថម្ភយើងណឹង ដល់គេធ្វើបាយរួមដាក់ស្រូវដាក់អន្ទុរទៅខ្លះទៅរួម ។

ឆាយៈ អ៊ីចឹងនៅដល់ឆ្នាំ ៧៥ ចុះនៅឆ្នាំ ៧៦ ពេលដែលខ្មែរក្រហមកាន់កាប់ធ្វើអីគេ?

វ៉ុតៈ ៧៦ យើងសន្តិភាពធ្វើស្រែមៅអីណោះហើយ មៅស្រុកយើងហើយ ។

ឆាយៈ កាលណឹងស្រុកយើងណឹងគេហៅតំបន់ប៉ុន្មាន?

វ៉ុតៈ តំបន់ ៣ ។

ឆាយៈ ចុះស្រុកគេមានផ្លាស់ប្តូរដាក់ថាស្រុកអីគេ?

វ៉ុតៈ ស្រុកគោកឃ្មុំហ្អែស...

ឆាយៈ ហ្អេ..!អានេះឃុំទេហ្អែស?

វ៉ុតៈ ឃុំគោកឃ្មុំ...ស្រុកថ្មគោល ។

ឆាយៈ អ៊ីចឹងនៅដដែលអត់មានផ្លាស់ប្តូរអីទេហ្អែស?

វ៉ុតៈ ចា៎!អត់មានផ្លាស់ប្តូរទេ ។

ឆាយៈ ចុះ ចៅហ្វាយស្រុកអីពីណាគេកាលឆ្នាំ ៧៦?

វ៉ុតៈ ពីណាទេខ្ញុំមិនដឹងផង ។

ឆាយៈ កាលណឹងខាងនារតីអត់ទាន់មៅទេហ្អែស?

វ៉ុតៈ ....?

ឆាយៈ នារតីមៅចុងឆ្នាំ ៧៧ ដើមឆ្នាំ ៧៨ ហើយ...អ៊ីចឹងពេលពួកនារតីមៅមានស្គាល់ពីណាទេ
នៅស្រុកនៅតំបន់ណឹង?

វ៉ុតៈ អត់ស្គាល់ទេ ។

ឆាយៈ ប៉ុន្តែរបបហូបចុកអីគេឲ្យហូបយ៉ាងម៉េចដែរ?

វ៉ុតៈ ហូបបបរដែរ ។

ឆាយៈ ខ្ញុំឮគេថាខាងតំបន ៣ ហូបចុកអីធូរជាងតំបន់ ៤ ហ្អាស...មែនទេ?

វ៉ុតៈ ហូបបបរណឹងឯង ។

ឆាយៈ បបរប៉ុន្តែបានបបរគោកហូបឆ្អែតហ្អែស?

វ៉ុតៈ ភាវដែរណឹង...ម៉ាខ្ទុះត្នោត ៣ កំប៉ុង ឆ្នាំ ៧៦ ,៧៧ណាឯង ។

ឆាយៈ អ៊ីចឹងឆ្នាំ ៧៦ គេបង្កើតសហករណ៍ដូចថាធ្វើរួមហូបរួមអស់ហើយនែស៎?

វ៉ុតៈ ចា៎! ឆ្នាំ ៧៦ គេបង្កើតហើយ ។

ឆាយៈ ចុះការងារពលកម្មអ៊ីគេអោយធ្វើអី?

វ៉ុតៈ ចូលដីបូងកាន់ដៃគ្នាទទ្រាំស្មៅឲ្យខ្មេចសំរាប់ស្ទូង ដូចខ្ញុំអីគេអោយដកសំណាបស្ទូង ។

ឆាយៈ

ចុះមីងគេអត់មានជម្លៀសផ្លាស់ទីកន្លែងទៅណាទេ..ក្រៅពីយើងទៅ នៅកំពីងពួយហើយគេមាន ឲ្យទៅ នៅអីណាទៀតទេឬក៏ទៅ នៅកំពីងពួយណឹងរហូតដល់បែក ៧៩ ណឹងហ្នងឬយ៉ាម៉េច?

វ៉ុតៈ ទៅ នៅកំពីងពួយរហូតដល់សន្តិភាព ។

ឆាយៈ អ៊ីចឹងទៅ នៅហ្នឹងអត់មានអីប្រែប្រួល...អត់មាននារតីម៉ៅគ្រប់គ្រងទេនែស៎?

វ៉ុតៈ មាននារតីអីណាចូលនៅហ្នឹង ។

ឆាយៈ អូ!អត់មានចូលដល់ណឹងទេនែស?

វ៉ុតៈ អត់ទេ ។

ឆាយៈ អ៊ីចឹងការហូបចុកអីយើងធ្វើបានប៉ុន្មានយើងហូបខ្លួនឯង?

វ៉ុតៈ ចា៎!

ឆាយៈ នៅក្នុងសហករណ៍ណឹងទៅ?

វ៉ុតៈ ចា៎!

ឆាយៈ ចុះកូនចៅគេយកទៅដាក់នៅអង្គភាពប្រមុលផ្តុំដែរ?

វ៉ុតៈ មានកូនឯណាយកទៅដាក់ខ្ញុំនោះ ។

ឆាយៈ គេផ្សេងៗអីហ្អាស៎?

វ៉ុតៈ គេមានកូនគេយកទៅ ។

ឆាយៈ ចុះអាការងារពលកម្មអីអត់មានសួរយ៉ាប់ទេហ្អែស៎..គេអត់មានដាក់ផែនការទេ..?

វ៉ុតៈ ខ្ញុំអត់ដែលធ្វើស្រែទេប៉ុន្មានឆ្នាំនេះ ។

ឆាយៈ ហឹអត់ធើស្រែធ្វើអីទៅ?

វ៉ុតៈ ធ្វើចំការ ។

ឆាយៈ ធ្វើចំការណឹងដាំអីខ្លះ?

រ៉ុតៈ ដាំពោត ដាំថ្នាំជក់ខ្លះទៅ ។

ឆាយៈ ពេលបានផលគេយកទៅណា?

រ៉ុតៈ ដាក់សហករណ៍ណឹងចែកឲ្យពុកៗទៅ ។

ឆាយៈ ហើយគេចែកឲ្យយើងហូបគ្រប់ៗគ្នាវិញទៅនែស៎?

រ៉ុតៈ ចា៎!

ឆាយៈ ប៉ុន្តែអាការចែកណឹងយើងធ្វើច្រើនគេចែកឲ្យច្រើនធ្វើតិចគេចែកឲ្យតិចចឹងហ្មងហ្អែស៎?

រ៉ុតៈ ចែកតាមកូនអីចឹងទៅ ។

ឆាយៈ បា!

រ៉ុតៈ ប៉ុន្តែខ្ញុំអត់កូនច្រើន នឹងគេមានតែឪ និម៉ែ... ។

ឆាយៈ គេឲ្យហូបម៉ាគ្រប់ដែរនែស៎?

រ៉ុតៈ ចា៎!

ឆាយៈ មិនកំណត់ថាឲ្យហូបអង្ករ ១ កំប៉ុងគ្នា ១០ នាក់អីចឹងទេហ្អែស៎?

រ៉ុតៈ កន្លែងខ្ញុំមិនដឹបូងអង្ករស្រូវយើងគ្រប់គ្រាន់ ដល់ ៧៥
បានខ្ញុំខ្លះបានខ្ញុំម៉ៅធ្វើស្រែនៅអាយអី ណោះ
នៅអីណោះអត់មានធ្វើស្រែកើតទេវាទើសព្រៃ ។

ឆាយៈ បាទ! ឈើច្រើនពេកភ្ជួរមិនកើតទេ មានគល់មានអី ដល់ ៧៥ ម៉ៅធ្វើស្រែអូរពោរនេះ
បានៗហូប ធ្វើនៅសហករណ៍ខ្នាចរមាស ។

រ៉ុតៈ បាទ!

ឆាយៈ

ហ៊ីអីចឹងគ្រួសារទាំងអស់ណឹងដែលយើងនាំគ្នាទៅតាមប្ដីទាំងអស់ណឹង..ប្រពន្ធនៅបង្ក
បង្កើនផល ហើយប្ដីចូលធ្វើទ័ពទាំងអស់គ្នាឬក៏ម៉េច?

រ៉ុតៈ ទេអាវៀងណឹងមិនដឹងអ្នកណាទៅ ធ្វើខ្លះទៅខ្ញុំមិនអ្នកស្រូវស្គាល់គេទេណាស៎ ។

ឆាយៈ អ្នកណាចូលៗទៅអ្នកណាមិនចូលក៏អត់ទៅឬក៏ម៉េច?

រ៉ុតៈ បែបអីចឹងឯង ព្រោះប្ដីខ្ញុំគាត់ចូលទៅខ្ញុំមិនដឹងអ្នកណាអ្នកណី ។

ឆាយៈ នៅតំបន់នេះបើតាមមីងនិយាយអាចធូរជាងតំបន់ ៤ ព្រោះខ្ញុំឮគេនិយាយថាការហូបចុកធូរជាងតំបន់ ៤ ។ ភាគច្រើនគេថានៅតំបន់ ៣ បានហូបបាយឆ្អែត ។

រ៉ុតៈ អត់ទេ ។

ឆាយៈ ម៉េចមីង? តំបន់ ៣ ណឹងអត់ដែរ?

រ៉ុតៈ អត់ដូចតែគ្នាបបរ រលីបរលាប ។

ឆាយៈ អ៊ីចឹង!

រ៉ុតៈ ចា៎! ហ៊ីដែលចូលទៅមុនដំបូងពេលអាពតដេញទៅណឹងខ្ញុំទៅ គោកក្តួចនេះអាក្អួន ។

ឆាយៈ បាទ!

រ៉ុតៈ អាក្អួនហ្នឹងអត់ស៊ីជួបគ្នាវាយកកន្ទក់មៅចែក ពេលចែកហើយអាខ្លះវាស៊ីចុកពោះស្រែកអូយៗ ។

ឆាយៈ អូ..!

រ៉ុតៈ ខ្ញុំចេះតែស៊ីបន្តិចៗទៅ ហើយប្តីខ្ញុំចេះធ្វើទ្រូ ១ ដាក់បានត្រីបានខ្យងទៅអត់ហូបទេកន្ទក់..អាខ្លះចុកពោះអាខ្លះហើម ។

ឆាយៈ ចុះកាលណឹងមានអ្នក ១៧ គេបញ្ជូនមៅខាងណឹងដែរទេ?

រ៉ុតៈ អត់ដឹង ។

ឆាយៈ អត់ដឹងទេ...

ឆាយៈ ចុះមីងថាគេចែកកន្ទក់ចែកអីគ្នាហូបណឹងនៅឆ្នាំណា?

រ៉ុតៈ ឆ្នាំ ៧៥ ណឹង...ហ៊ីគ្នាសរសៃខ្ចីហូបកន្ទក់ទៅវាហើម ។

ឆាយៈ ចុះកាលសម័មីងអ៊ើយ

មានក្រុមគ្រួសារដែលត្រូវរងទារុណកម្មអីពីរបបណឹងដែរទេ? ដូចថាធ្វើពលកម្មមិនដិតដល់គេធ្វើបាបធ្វើអី?

រ៉ុតៈ អត់មានទេ ។

ឆាយៈ ហ៊ីមានឃើញពីណាដែលនៅជាមួយមីងអីចឹងនៅសុខៗស្រាប់តែបាត់ខ្លួនទៅមានទេ?

រ៉ុតៈ អត់ទេ ។

ឆាយៈ ដូចថាអត់មានពីណាបាត់ខ្លួននៅក្នុងសម័យណឹងទេនែស៎?

រ៉ុតៈ សម័យណឹងបាត់ខ្លួនគ្នាច្រើនណាស់ ប៉ុន្តែបែកបាក់ម៉ែឪទេណាទៅណីអស់ហើយ ។

ឆាយៈ	នៅក្នុងអង្គភាពជាមួយគ្នាក៏ដោយ.?

វុតៈ	នៅក្នុងសហករជាមួយគ្នាតែមិនដឹងទៅដល់ណាទេ ។

ឆាយៈ	មានដឹងថាពេលកំពុងធ្វើការជាមួយគ្នាពីម្សិលហើយស្រាប់តែថ្ងៃនេះបាត់អត់ឃើញមនុស្ស ណឹងមានធ្លាប់ឃើញទេ?

វុតៈ	មិនបានជាចាំទុកផង ប៉ុន្តែកូនមីង សយ ផន នេះ គេវ៉ៃចោលតែមិនដឹងវ៉ៃអីណាទេ ។

ឆាយៈ	មីងមានឃើញគេយកទៅ ទេ?

វុតៈ	អត់ទេ ។

ឆាយៈ	គ្រាន់តែឮៗ ទេ?

វុតៈ	ចា៎!

ឆាយៈ	ចុះមានអ្នកណាផ្សេងទៀតទេដែលគេយកទៅ វ៉ៃចោល?

វុតៈ	អត់ទេឮតែម្នាក់ណឹងក៏ស្លាត់ទៅ ។

ឆាយៈ	អ្នកដែលនៅបឹងកំពីងពួយណឹងនៅ ត្រង់ណឹងតំបន់ដាច់ពីគេហ្នឹងហ្អែស៎?

វុតៈ	មានដាច់អីវាកំប៉េតកំប៉ូតតាមព្រៃអីចឹងណា៎ ។

ឆាយៈ	តែវាដាច់ឆ្ងាយពីភូមិពីស្រុកយើងដែរនែស៎?

វុតៈ	ដាច់ឆ្ងាយដែរអីណោះ ។

ឆាយៈ	បាទ! ផុតពីវាទៅៗដល់បឹងណឹងហ្នឹងហ្អែស៎?

វុតៈ	ចា៎! នៅព្រៃ ។

ឆាយៈ	បាទ! កាលណឹងពីណាគេនៅ គ្រប់គ្រងហ្នឹងធំជាងគេ?

វុតៈ	អត់ស្គាល់ទេមិនអ្នកដើរមិនអ្នកអីទេនៅតែផ្ទះមើលតែកូន មិនដឹងអ្នកណាធំអ្នកណាតូច អីខ្ញុំ ស្រេចហើយ មិនសូវចេះសួរនាំអីគេទេខ្លាចគេ ។

ឆាយៈ	អីចឹងក្រោយ ៧៩ ហើយមីងមោដល់ស្រុកភូមិវិញមីញមានបាត់ក្រុមគ្រួសារនៅក្នុងស្រុក ក្នុងភូមិណឹងទេ ។

វុតៈ	អត់ ។

ឆាយៈ	អត់មានបាត់ទេនៅទាំងអស់...

វុតៈ	ចា៎!

ឆាយៈ	រហូតមោដល់ឥឡូវអត់មានថាអ្នកណាបាត់ក្នុងសម័យណឹងទេនែស៎?

រ៉ុតៈ ចា៎! បើបាត់ៗបងប្អូនខាងប្ដីខ្ញុំឈ្មោះអាអីកូនមីង ឡៀប នោះ...។

ឆាយៈ អីចឹងមីងនៅសម័យណឹងមិនសូវបានជួបប្រទះការធ្វើទារុណកម្ម

មិនសូវបានដូចថាការលត់ដំ ខ្លាំងក្លាប៉ុន្មានទេមីងហ៊ែ្ហ?

រ៉ុតៈ អត់ទេ ។

ឆាយៈ វាអត់ដូចនៅតំបន់ផ្សេងៗហ្អាស់?

រ៉ុតៈ ចា៎!

ឆាយៈ ព្រោះមីងបានទៅខាងកំពីងពួយណឹងជាតំបន់ដាច់ពីគេ ។

រ៉ុតៈ ចា៎! ៣ឆ្នាំណឹងយើងហូបតែបាយខ្ជួនយើង ។

ឆាយៈ ហូបបាយខ្ជួនយើងរហូតនែស៎?

រ៉ុតៈ ចា៎!

ឆាយៈ ចុះមីងថាគេបង្កើតសហករណ៍..?

រ៉ុតៈ គេបង្កើតសហករណ៍ណឹងមៅជិត ៧៥ ហើយណឹង ពេលគេជិតសន្តិបាពហើយ..។

ឆាយៈ សន្តិភាពណឹងពេលដែលបែកលន់ ណុលណឹងហ៊ែ្អស៎?

រ៉ុតៈ ៧៥

ដែលថាសន្តិភាពណឹងហ្អស៎...អាពតចូលហើយ..ណឹងបានមៅធ្វើស្រែអីណោះ..បានធ្វើសហករណ៍ទៅចែកបាយហូប ។

ឆាយៈ នៅក្នុងភូមិកណ្ដាលណឹងវិញហ៊ែ្អស៎?

រ៉ុតៈ អត់ទេ..! នៅអីណោះ ។

ឆាយៈ នៅកំពីងពួយណឹងដដែល?

រ៉ុតៈ ចា៎!

ឆាយៈ បាទ! រហូតមោដល់ឥឡូវនេះមីងមានដែលឮពត៌មានគេបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

រ៉ុតៈ អត់ ។

ឆាយៈ អត់មាដែលឮអ្នកណានិយាយអីពីរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗណឹងទេហ៊ែ្អស៎?

រ៉ុតៈ អត់ទេ ។

ឆាយៈ ឥឡូវរដ្ឋាភិបាលហើយ
និងអង្គការសហប្រជាជាតិកំពុងតែដំណើរការរឿងតុលាការកាត់ទោស
មេដឹកនាំខ្មែរក្រហមណឹង ។ចុះចំណែកមីងវិញយល់ថាការបង្កើតតុលាករណឹងយ៉ាងម៉េចដែរ
មីងគិតថាល្អឬក៏អាក្រក់យ៉ាងម៉េច?

រ៉ុតៈ មិនដឹងយ៉ាងម៉េចទេខ្ញុំមិនសូវចេះអក្សរផង ។

ឆាយៈ មីងមិនសូវមានទទួលរងការឈឺចាប់ប៉ុន្មានទេព្រោះអត់មានក្រុមគ្រួសាបាត់បង់
បាត់តែប្តីម្នាក់
អីចឹងបើសិនជាកុលាការណឹងដំណើរការកាត់ក្តី មេដឹកនាំខ្មែរក្រហមវាអាចផ្តល់អីខ្លះដល់ប្រជា
ជនយើងទូទាំងប្រទេស ផ្តល់អីខ្លះដល់មីងម៉ាចំណែកដែរ? តើមីងអាចយល់ថាតុលាការណឹង
អាចផ្តល់អ្វីដល់មីងខ្លះដែរឬក៏អាចផ្តល់ឲ្យប្រជាជនយើងខ្លះដែរទេ?

រ៉ុតៈ ដឹងអី..ស្រេចតែអ្នកធ្វើការណឹងឯង..ខ្ញុំមិនដឹង.. ។

ឆាយៈ មីងដឹងថាពាក្យយុត្តិធម៌មានន័យថាម៉េច?

រ៉ុតៈ ថាម៉េចទេខ្ញុំមិនសូវចេះ ។

ឆាយៈ មានន័យថាម៉េច?

រ៉ុតៈ ...?

ឆាយៈ គេសំដៅទៅលើអីយុត្តិធម៌..មានអំពើល្អមានអំពើអាក្រក់អីចឹងហ្អស៎..?

រ៉ុតៈ សំដៅរកអំពើល្អណឹងឯងសព្វថ្ងៃណឹង ។

ឆាយៈ បាទ! ចុះបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមណឹងគិតថាជាអំពើល្អមួយសំរាប់យើងឬ
ក៏អាក្រក់សំរាប់យើង?

រ៉ុតៈ ....ខ្ញុំអត់សូវដឹងទេ?

ឆាយៈ បាទ!បើអីចឹងខ្ញុំអរគុណមីងហើយ បើមីងអត់សូវដឹងអីចឹង...ខ្ញុំអត់មានអីសួរមីងទៀតទេបើ
មីងនឹកឃើញចំណុចត្រង់ណាដែលមីងអាចប្រាប់ខ្ញុំបានមីងនិយាយមោ៉ចុះ ។

រ៉ុតៈ ខ្ញុំគ្រាន់តែចង់សួរថាគាត់ណឹងអាចរស់ឬក៏ទៅណា?

ឆាយៈ ដូចប្អូនបានជំរាបហើយម៉ិញណឹងហ្អស៎...ថាគាត់ត្រូវបានគេចាប់ខ្លួនយលទៅដាក់ទូលស្លែង
ហីយើងដឹងហើយថាតើគុកទួលស្លែងវាសាហាវប៉ុនណា...វាមិនអាចឲ្យមនុស្សដែលវាចាប់
ហើយបានរស់មោវិញទេ ។

ហើអ្នកដែលរស់រានរហូតដល់សព្វថ្ងៃណឹងមានដែរកាលបែកហើយ ណឹងរស់បាន ៧ នាក់ ប៉ុន្តែសព្វថ្ងៃណឹងស្លាប់អស់ ៤ នាក់ហើយ នៅតែ ៣ នាក់ទេ គឺឈ្មោះ តាណា, តាម៉ី ហើយនិងប៊ូ ម៉េង សព្វថ្ងៃនៅ ៣ នាក់ណឹង ។ ហើយអ្នកទាំង អស់ណឹងដូចថាសុទ្ធតែមានប្រយោជន៍ចំពោះគេហ្អាស៎ បានអាចរស់បាន ។ ដូចជាម្នាក់ជា ជាងឆ្លាក់រូប ហើយនិងជាថតអីចឹង ហើអ្នកទាំងអស់ណឹងសព្វថ្ងៃគាត់នៅសេ់បាន ៣ នាក់ ។ក្រោ ៧៩ គាត់នៅសល់ ៧ នាក់មែន តែក្រោយមោ៉គាត់ឈឺគាត់ចាស់ស្លាប់អស់ ទៅ ។ អីចចឹងចំពោះប្ដីមីងខ្ញុំអត់ដឹងថាគាត់នៅរស់ឬក៏ស្លាប់ទេ ប៉ុន្តែយើងគិតថារហូតមោ៉ ដល់ពេលនេះហើយបើសិនជាគាត់នៅរស់គាត់ប្រហែលជាមានពត៍មានមោ៉មីងហ្អើយ ។ពួកខ្ញុំ គ្រាន់តែបានពត៍មានថាគាត់ត្រូវបានគេចាប់ដាក់ទួលស្លែង ។ហើគិតថាបើនៅទួលស្លែងអីចឹង អ្នក ស្លាប់នោះវាស្លាប់អស់ ៩០ ភាគរយហើយអ្នករស់ណឹងវាតិចួចណាស់ ។ អីចឹងបើគាត់នៅ រស់គាត់ផ្ដល់ពត៍មានមោ៉មីងហ្អើយ ។ អីចឹងមើមីងគ្មាយោបល់អីជំរាបជូនពួកខ្ញុំទេ ខ្ញុំសូមអរគុណមីងហើយណាស៎ ។

រ៉ុត: ចា៎!

ឆាយ: បាទ!ខ្ញុំអរគុណមីងច្រើន...

-ចប់-